# ឱកាសធ្វើសេចក្តីល្អ

ប្រធាន ហិនរី ប៊ី អាវរិង
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

*របៀបរបស់ព្រះអម្ចាស់ដើម្បីជួយដល់អ្នកមានតម្រូវការខាងសាច់ឈាមតែងតែតម្រូវឲ្យមនុស្សដែលមានក្តីស្រឡាញ់ខ្លាំងលះបង់ខ្លួនឯងនិងអ្វីដែលគេមានថ្វាយព្រះ និងកិច្ចការរបស់ទ្រង់ ។*

បងប្អូនប្រុសស្រីជាទីស្រឡាញ់ គោលបំណងនៃសារលិខិតរបស់ខ្ញុំ គឺជាការគោរព និងការអបអរនូវអ្វីដែលព្រះអម្ចាស់បានធ្វើ និងកំពុងធ្វើដើម្បីបម្រើដល់ជនក្រីក្រ និងទុរគតក្នុងចំណោមកូនចៅទ្រង់លើផែនដីនេះ ។

ទ្រង់ស្រឡាញ់កូនចៅទ្រង់យ៉ាងខ្លាំងហើយនឹងអ្នកដែលចង់ជួយផងដែរ ។ ហើយទ្រង់បានបង្កើតរបៀបដើម្បីប្រទានពរដល់អ្នកដែលត្រូវការជំនួយ និងអ្នកដែលធ្វើកិច្ចការនេះ ។ ព្រះវរបិតាសួគ៌យើងស្តាប់ការអធិស្ឋានរបស់កូនចៅទ្រង់នៅទូទាំងផែនដី ដែលទូលអង្វរសុំអាហារបរិភោគ សំលៀកបំពាក់បិទបាំងរាងកាយ និងភាពថ្លៃថ្នូរដែលកើតចេញពីការមានលទ្ធភាពផ្គត់ផ្គង់ខ្លួនឯង ។

ទ្រង់បានស្តាប់ឮការទូលអង្វរទាំងនោះ ចាប់តាំងពីទ្រង់បានដាក់មនុស្សប្រុសស្រីលើផែនដីនេះម្ល៉េះ ។

អ្នករៀនពីក្តីត្រូវការទាំងនោះនៅកន្លែងដែលអ្នករស់នៅ និងនៅជុំវិញពិភពលោក ។ ជារឿយៗ ដួងចិត្តអ្នកមាននូវអារម្មណ៍អាណិតអាសូរ ។ ពេលអ្នកជួបមនុស្សម្នាក់ដែលពិបាកក្នុងការរកការងារធ្វើ នោះអ្នកមានបំណងចង់ជួយ ។

អ្នកមានអារម្មណ៍បែបនេះពេលអ្នកចូលទៅក្នុងផ្ទះស្ត្រីមេម៉ាយម្នាក់ ហើយឃើញគាត់ខ្វះអាហារ ។ អ្នកមានអារម្មណ៍បែបនេះពេលអ្នកឃើញរូបថតនៃកូនក្មេងស្រែកយំ ក្នុងការហិនហោចនៃផ្ទះគេដែលបានបំផ្លិចបំផ្លាញដោយការរញ្ជួយដី ឬភ្លើងឆេះ ។

ពីព្រោះ ព្រះអម្ចាស់ស្តាប់ឮការអំពាវនាវរបស់គេ ហើយយល់ពីការអាណិតរបស់អ្នកសម្រាប់គេ នោះទ្រង់បានផ្តល់វិធីសម្រាប់សិស្សទ្រង់ដើម្បីជួយតាំងពីដំបូងមកម្ល៉េះ ។ ទ្រង់បានអញ្ជើញកូនចៅទ្រង់ដើម្បីលះបង់ពេលវេលាខ្លួន មធ្យោបាយខ្លួន និងលះបង់ខ្លួនដើម្បីរួមដៃនឹងទ្រង់ក្នុងការបម្រើអ្នកដទៃ ។

វិធីរបស់ទ្រង់ដើម្បីជួយត្រូវបានហៅថា « ការរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ » ។ នៅក្នុងសម័យមួយទៀតរបៀបរបស់ទ្រង់ត្រូវបានហៅថា « សហសមាគម » ។ ក្នុងសម័យយើងវាត្រូវបានហៅថា « កម្មវិធីសុខុមាលភាពសាសនាចក្រ » ។

ឈ្មោះនិងព័ត៌មានលំអិតនៃដំណើរការនេះត្រូវបានប្តូរដើម្បីសមស្របនឹងតម្រូវការនិងលក្ខខណ្ឌនៃមនុស្ស ។ តែរបៀបរបស់ព្រះអម្ចាស់ដើម្បីជួយដល់អ្នកមានតម្រូវការខាងសាច់ឈាមតែងតែតម្រូវឲ្យមនុស្សដែលមានក្តីស្រឡាញ់ខ្លាំងលះបង់ខ្លួនឯង និងអ្វីដែលគេមានថ្វាយព្រះ និងកិច្ចការរបស់ទ្រង់ ។

ទ្រង់បានអញ្ជើញនិងបញ្ជាយើងឲ្យចូលរួមក្នុងកិច្ចការទ្រង់ដើម្បីលើកស្ទួយដែលអ្នកដែលទ័លក្រ ។ យើងចុះសេចក្តីសញ្ញាមួយដើម្បីកិច្ចការនេះ ក្នុងទឹកនៃបុណ្យជ្រមុជទឹកនិងក្នុងព្រះវិហារបរិសុទ្ធនៃព្រះ ។ យើងរំឭកចាំសេចក្តីសញ្ញានោះនៅថ្ងៃអាទិត្យ ពេលយើងទទួលទានសាក្រាម៉ង់ ។

គោលបំណងខ្ញុំនៅថ្ងៃនេះគឺចង់រៀបរាប់ពីឱកាសមួយចំនួនដែលទ្រង់បានប្រទានឲ្យយើង ដើម្បីជួយអ្នកដែលទ័លក្រ ។ ខ្ញុំមិនអាចនិយាយវាទាំងអស់ក្នុងពេលដ៏ខ្លីនេះបានឡើយ ។ ក្តីសង្ឃឹមរបស់ខ្ញុំគឺដើម្បីរំឭក និងពង្រឹងដល់ការតាំងចិត្តរបស់ដើម្បីអនុវត្ត ។

មានទំនុកតម្កើងមួយពីការអញ្ជើញរបស់ព្រះអម្ចាស់ចំពោះកិច្ចការនេះ ដែលខ្ញុំធ្លាប់ច្រៀងតាំងពីខ្ញុំនៅក្មេងម្ល៉េះ ។ កាលពីក្មេង ខ្ញុំផ្តោតទៅលើទំនុកភ្លេងដ៏រីករាយជាងឥទ្ធិពលនៃទំនុកច្រៀង ។ ខ្ញុំសូមអធិស្ឋានថា អ្នកនឹងយល់ពីទំនុកច្រៀងនោះក្នុងដួងចិត្តនាថ្ងៃនេះ ។ ចូរយើងស្តាប់ទំនុកច្រៀងនោះម្តងទៀត ៖

*តើនៅថ្ងៃនេះខ្ញុំបានធ្វើរឿងល្អសម្រាប់ពិភពលោកដែរទេ ?*
*តើខ្ញុំបានជួយអ្នកដែលទ័លក្រដែរទេ ?*
*តើខ្ញុំបានសម្រាលទុក្ខអ្នកសោកសៅ ហើយឲ្យគេរីករាយដែរទេ ?*

*បើមិនដូច្នោះ ខ្ញុំពិតជាបរាជ័យហើយ ។*
*តើនៅថ្ងៃនេះមានបន្ទុករបស់មនុស្សត្រូវបានធូរស្រាល*
*ដោយសារខ្ញុំបានស្ម័គ្រចិត្តជួយដែរទេ ?*
*តើមានអ្នកឈឺនិងអ្នកនឿយហត់បានទទួលជំនួយតាមតម្រូវការដែរទេ ?*

*ពេលគេត្រូវជំនួយពីខ្ញុំតើខ្ញុំបាននៅទីនោះដែរទេ ?*
*អញ្ចឹង ចូរភ្ញាក់ឡើងហើយធ្វើអ្វីមួយដែលលើសពី*
*ក្តីស្រមៃនៃរង្វាន់របស់អ្នកនៅឯស្ថានសួគ៌ ។*
*ការធ្វើល្អជារឿងរីករាយ ជាក្តីអំណរដែលមិនអាចថ្លែងបាន*
*ជាពរជ័យនៃភារកិច្ចនិងក្តីស្រឡាញ់ ។*[1]

ព្រះអម្ចាស់បានសារដាស់តឿនដល់យើងរាល់គ្នាជាទៀងទាត់ ។ ពេលខ្លះ វាអាចជាអារម្មណ៍នៃការអាណិតភ្លាមៗសម្រាប់អ្នកដែលទ័លក្រ ។ ឪពុកម្នាក់អាចមានអារម្មណ៍បែបនោះ ពេលគាត់ឃើញកូនម្នាក់ដួលរលាត់ក្បាលជង្គង់ ។

ម្ដាយម្នាក់អាចមានអារម្មណ៍នេះ ពេលគាត់ឮកូនខ្លួនយំយ៉ាងខ្លាំងនាពេលយប់ ។ កូនប្រុស ឬកូនស្រីម្នាក់អាចមានអារម្មណ៍អាណិតអាសូរដល់មនុស្សម្នាក់ដែលមានភាពសោកសៅ ឬភ័យខ្លាចនៅឯសាលា ។

យើងគ្រប់គ្នាធ្លាប់មានអារម្មណ៍នៃការអាណិតអាសូរចំពោះអ្នកដទៃដែលយើងមិនធ្លាប់ស្គាល់ ។ ឧទាហរណ៍ ពេលអ្នកឮសេចក្ដីរាយការណ៍ពីទឹករលកកំពុងបោកបក់កាត់មហាសមុទ្រប៉ាស៊ីហ្វិក ដែលបណ្ដាលមកពីការរញ្ជួយដីនៅជប៉ុន នោះអ្នកមានអារម្មណ៍ខ្វល់ខ្វាយចំពោះអ្នកដែលអាចទទួលរងគ្រោះ ។

អារម្មណ៍នៃការអាណិតអាសូរកើតមានអ្នករាល់គ្នារាប់ពាន់នាក់ ដែលបានដឹងពីទឹកជំនន់នៅ ឃ្វីនស៍ឡែន ប្រទេសអូស្ត្រាលី ។ សារព័ត៌មានបានស្ទង់មើលពីចំនួនមនុស្សជាច្រើនដែលត្រូវការជំនួយ ។ តែអ្នករាល់គ្នាជាច្រើនបានយល់ពីការឈឺចាប់នៃអ្នកទាំងនោះ ។ សារដាស់តឿនត្រូវបានឆ្លើយតបដោយអ្នកស្ម័គ្រជាសមាជិកសាសនាចក្រចំនួន 1500 នាក់ឬច្រើនជាងនេះ ក្នុងប្រទេសអូស្ត្រាលី ជាអ្នកដែលបានមកជួយលួងលោម ។

គេបានបង្វែរអារម្មណ៍នៃការអាណិតអាសូររបស់ខ្លួនឲ្យក្លាយជាការសម្រេចចិត្តមួយដើម្បីអនុវត្តនូវសេចក្តីសញ្ញារបស់គេ ។ ខ្ញុំធ្លាប់ឃើញពរជ័យដែលកើតមានចំពោះអ្នកដែលទ័លក្រ ដែលបានទទួលជំនួយនិងអ្នកដែលយកឱកាសធ្វើកិច្ចការនេះ ។

ឪពុកម្ដាយដ៏ឈ្លាសវៃឃើញនូវគ្រប់តម្រូវការរបស់អ្នកដទៃ ជាផ្លូវមួយដើម្បីនាំពរជ័យមកក្នុងជីវិតកូនប្រុសស្រីរបស់ខ្លួន ។ ថ្មីៗនេះ មានក្មេងបីនាក់បានឈរនៅមុខទ្វារផ្ទះយើង ដោយកាន់ប្រអប់ដែលមានអាហារពេលល្ងាចដ៏ឆ្ងាញ់ក្នុងនោះ ។ ឪពុកម្ដាយគេបានដឹងថា យើងត្រូវការជំនួយ ហើយបានដាក់បញ្ចូលកូនរបស់គេនៅក្នុងឱកាសបម្រើដល់យើង ។

ឪពុកម្ដាយនោះបានប្រទានពរដល់យើងដោយការបម្រើដ៏សប្បុរសរបស់គេ ។ ដោយការជ្រើសរើសឲ្យកូនពួកគេចូលរួមក្នុងការបម្រើនេះ ពួកគេបានផ្ដល់ពរជ័យដល់កូនរបស់ពួកគេដែរ ។ ស្នាមញញឹមរបស់ក្មេងទាំងនោះ ពេលគេបានដើរចេញពីផ្ទះរបស់យើង បានធ្វើឲ្យខ្ញុំជឿជាក់ថាការណ៍នោះនឹងកើតឡើង ។

គេនឹងប្រាប់កូនរបស់គេពីក្ដីអំណរដែលគេមានក្នុងការធ្វើការបម្រើដ៏សប្បុរសដល់ព្រះអម្ចាស់ ។ ខ្ញុំចាំថា អារម្មណ៍នៃភាពរីករាយដ៏ស្ងៀមស្ងាត់កាលពីក្មេង ពេលខ្ញុំបានដកស្មៅឲ្យអ្នកជិតខាងម្នាក់តាមការស្នើសុំរបស់ឪពុកខ្ញុំ ។ កាលណាខ្ញុំត្រូវបានសុំឲ្យបម្រើ ខ្ញុំបានចាំហើយជឿជាក់លើទំនុកតម្កើងដែលចែងថា « កិច្ចការដ៏ផ្អែម ឱ ព្រះនៃខ្ញុំ » ។[2]

ខ្ញុំដឹងថា ទំនុកច្រៀងនោះត្រូវបាននិពន្ធឡើងដើម្បីរៀបរាប់ពីក្ដីអំណរដែលកើតចេញពីការថ្វាយបង្គំដល់ព្រះអម្ចាស់នៅថ្ងៃឈប់សម្រាក ។ តែក្មេងដែលឈរនៅមុខផ្ទះរបស់យើងបានយល់ពីក្ដីអំណរនៃការធ្វើកិច្ចការរបស់ព្រះអម្ចាស់នៅយប់ថ្ងៃធម្មតាមួយ ។ ហើយឪពុកម្ដាយគេបានឃើញនូវឱកាសដើម្បីធ្វើរឿងល្អ ហើយផ្សាយក្ដីអំណរដល់ជំនាន់ជាច្រើន ។

របៀបរបស់ព្រះអម្ចាស់នៃការមើលថែអ្នកទ័លក្រ ផ្ដល់ជាឱកាសមួយទៀត ដើម្បីឪពុកម្ដាយអាចប្រទានពរដល់កូនចៅខ្លួន ។ ខ្ញុំបានឃើញព្រឹត្តិការណ៍នៅរោងថ្វាយបង្គំនាថ្ងៃអាទិត្យមួយ ។ មានក្មេងតូចម្នាក់បានហុចស្រោមសំបុត្រប្រាក់ដង្វាយឲ្យប៊ីស្សព ពេលគាត់ចូលមកក្នុងរោងថ្វាយបង្គំពីមុនការប្រជុំសាក្រាម៉ង់ ។

ខ្ញុំបានស្គាល់ក្មេងប្រុស និងគ្រួសារនោះ ។ គ្រួសារនោះទើបដឹងថា មានសមាជិកម្នាក់ក្នុងវួដដែលត្រូវការជំនួយ។ ឪពុកបាននិយាយបែបនេះទៅក្មេងនោះ ពេលគាត់បានដាក់ដង្វាយតមអាហារដ៏ច្រើនជាងធម្មតានៅក្នុងស្រោមសំបុត្រនោះ ។

« យើងតមអាហារនៅថ្ងៃនេះ ហើយបានអធិស្ឋានដល់អ្នកដែលទ័លក្រ ។ ចូរឲ្យស្រោមសំបុត្រនេះទៅប៊ីស្សពជំនួសប៉ាម៉ាក់ផង ។ ប៉ាដឹងថា គាត់នឹងប្រើវាដើម្បីជួយអ្នកមានតម្រូវការខ្លាំងជាងយើង » ។

ជំនួសឲ្យការស្រេកឃ្លាននានានៅថ្ងៃអាទិត្យនោះ ក្មេងប្រុសនោះនឹងចងចាំនូវថ្ងៃមួយដែលមានអារម្មណ៍ដ៏រីករាយ។ ខ្ញុំអាចដឹងតាមរយៈស្នាមញញឹមនិងរបៀបដែលគាត់កាន់ស្រោមសំបុត្រនោះយ៉ាងជាប់ រហូតដល់គាត់មានការទុកចិត្តយ៉ាងខ្លាំងចំពោះឪពុកគាត់ ដើម្បីយកប្រាក់ដង្វាយរបស់គ្រួសារសម្រាប់អ្នកក្រីក្រ ។ គាត់នឹងចាំថ្ងៃនោះ ពេលគាត់ក្លាយជាឌីកុន និងប្រហែលជារៀងរហូត ។

ខ្ញុំបានឃើញសុភមង្គលដូចគ្នានេះលើផ្ទៃមុខរបស់អ្នកដែលបានជួយដល់មនុស្សទូទៅជំនួសព្រះអម្ចាស់ក្នុងទីក្រុង អៃដាហូ កាលពីច្រើនឆ្នាំកន្លងទៅ ។ ទំនប់ទឹក ធេធិន បានធ្លាយបែកនៅថ្ងៃសៅរ៍ ទី 5 ខែ មិថុនា ឆ្នាំ 1976 ។ មានមនុស្សដប់មួយនាក់បានស្លាប់ ។ មនុស្សរាប់ពាន់នាក់ត្រូវចុះចោលផ្ទះសម្បែងខ្លួនក្នុងរយៈពេលតែប៉ុន្មានម៉ោង ។ មានផ្ទះមួយចំនួនត្រូវហូរតាមទឹក ។ ហើយផ្ទះដែលនៅសេសសល់គឺជារងការខូចខាតជាខ្លាំងដែលហួសពីលទ្ធភាពរបស់ម្ចាស់ផ្ទះ ។

អ្នកដែលបានឮពីគ្រោះមហន្តរាយនេះ មានការអាណិតអាសូរ ហើយមានអារម្មណ៍ចង់ធ្វើនូវរឿងល្អ ។ មានអ្នកជិតខាង ប៊ីស្សព ប្រធានសមាគមសង្គ្រោះ អ្នកដឹកនាំកូរ៉ុម គ្រូបង្រៀនសួរសុខទុក្ខ និងគ្រូបង្រៀនតាមផ្ទះបានចេញពីផ្ទះ និងឈប់សម្រាកពីការងារដើម្បីសម្អាតផ្ទះរបស់អ្នកដទៃដែលរងនូវទឹកជំនន់ ។

មានស្វាមីភរិយាមួយគូបានត្រឡប់មក រ៉េក្សប៊ឺហ្គ ពីការដើរលេងរបស់ខ្លួន ក្រោយពីទឹកជំនន់នោះ ។ គេមិនបានទៅមើលផ្ទះរបស់គេឡើយ ។ តែ គេបានស្វែងរកប៊ីស្សពរបស់គេ ដើម្បីសួរពីទីកន្លែងដែលពួកគេអាចជួយ ។ គាត់បាននាំពួកគេទៅរកគ្រួសារមួយដែលត្រូវការជំនួយ ។

ប៉ុន្មានថ្ងៃក្រោយមក គេបានទៅមើលស្ថានភាពផ្ទះរបស់គេ ។ វាត្រូវបានទឹកជំនន់បោកបក់ហូរយកទៅជាមួយអស់ហើយ ។ គេបានដើរត្រឡប់ទៅរកប៊ីស្សពវិញ ហើយបានសួរថា « ឥឡូវ តើលោកចង់ឲ្យយើងធ្វើអ្វី ? »

មិនថាអ្នករស់នៅទីណានោះទេ អ្នកបានឃើញពីអព្ភូតហេតុនៃការអាណិតអាសូរបានប្រែក្លាយជាអំពើអាត្មានិយម ។ វាប្រហែលជាមិនមែនចេញពីលទ្ធផលនៃគ្រោះធម្មជាតិដ៏ធំនោះឡើយ ។ ខ្ញុំបានឃើញព្រឹត្តិការណ៍នេះនៅក្នុងកូរ៉ុមបព្វជិតភាពមួយ ពេលមានបងប្រុសម្នាក់បានក្រោកឈរឡើងប្រាប់ពី

សេចក្តីត្រូវការរបស់បុរស ឬស្ត្រីម្នាក់ ដែលស្វែងរកការងារធ្វើដើម្បីផ្គត់ផ្គង់ខ្លួនឯង និងគ្រួសារ ។ ខ្ញុំអាចឃើញពីការអាណិតអាសូរនៅក្នុងក្វុំមនោះ តែមានមនុស្សមួយចំនួនបានឲ្យឈ្មោះមនុស្សដែលអាចត្រូវការអ្នកដែលចង់បានការងារធ្វើទៅវិញ ។

អ្វីដែលកើតឡើងក្នុងក្វុំមបព្វជិតភាពនោះ និងអ្វីដែលកើតឡើងក្នុងផ្ទះដែលរងទឹកជំនន់នៅអៃដាហូ គឺជាការបង្ហាញពីរបៀបរបស់ព្រះអម្ចាស់ដើម្បីជួយដល់អ្នកដែលការជំនួយជាខ្លាំង ដើម្បីមានភាពខ្លួនទីពឹងខ្លួនម្តងទៀត ។ យើងមានការអាណិតអាសូរ ហើយយើងដឹងពីរបៀបជួយតាមវិធីរបស់ព្រះអម្ចាស់ ។

យើងអបអរនូវគម្រប់ខួបលើកទី 75 នៃកម្មវិធីសុខុមាលភាពសាសនាចក្រក្នុងឆ្នាំនេះ ។ វាត្រូវបានផ្តើមឡើងដើម្បីបំពេញតម្រូវការនៃអ្នកដែលបាត់បង់ការងារ បាត់បង់កសិដ្ឋាន រួមទាំងផ្ទះដែរ ដែលបណ្តាលមកពីអ្វីយើងស្គាល់ថាជា « គ្រានៃវិបត្តិសេដ្ឋកិច្ចដ៏ធំ » ។

តម្រូវការខាងសាច់ឈាមដ៏ធំនៃកូនចៅរបស់ព្រះវរបិតាសួគ៌ បានកើតមានម្តងទៀតនៅក្នុងជំនាន់របស់យើង ដូចដែលវាធ្លាប់កើតមាន និងដូចដែលវាកើតមានគ្រប់សម័យកាល ។ គោលការណ៍ទាំងឡាយនៅក្នុងគ្រឹះនៃកម្មវិធីសុខុមាលភាពសាសនាចក្រគឺមិនមែនសម្រាប់តែគ្រាមួយ ឬកន្លែងមួយនោះឡើយ ។ វាគឺសម្រាប់គ្រប់ពេលគ្រប់វេលាទាំងអស់ ។

គោលការណ៍ទាំងនោះគឺជារឿងខាងវិញ្ញាណនិងអស់កល្ប ។ ចំពោះហេតុផលនោះ ដោយការយល់វានិងដាក់វាចូលទៅក្នុងដួងចិត្តយើង នឹងធ្វើឲ្យយើងអាចឃើញ ហើយក្តាប់យកឱកាសដើម្បីជួយនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាដែលព្រះអម្ចាស់ត្រូវការយើង ។

នេះគឺជាគោលការណ៍មួយចំនួនដែលដឹកនាំខ្ញុំ ពេលខ្ញុំចង់ជួយតាមរបៀបរបស់ព្រះអម្ចាស់ និងពេលខ្ញុំបានទទួលជំនួយពីអ្នកដទៃ ។

ទីមួយ មនុស្សគ្រប់គ្នាមានភាពរីករាយ និងភាពជឿជាក់ច្រើនឡើង ពេលគេអាចផ្គត់ផ្គង់ដល់ខ្លួនឯង និងគ្រួសារ រួចហើយឈោងទៅជួយមើលថែដល់អ្នកដទៃ ។ ខ្ញុំមានអំណរគុណចំពោះអ្នកដែលបានជួយខ្ញុំឲ្យបំពេញតម្រូវការខ្ញុំ ។ ហើយខ្ញុំបានមានអំណរគុណអស់រយៈពេលជាច្រើនឆ្នាំ ដល់អ្នកដែលជួយខ្ញុំឲ្យមានភាពខ្លួនទីពឹងខ្លួន ។ រួចហើយខ្ញុំមានអំណរគុណបំផុតដល់អ្នកដែលបានបង្ហាញខ្ញុំពីរបៀបដើម្បីធនធានរបស់ខ្ញុំមួយចំនួន ដើម្បីជួយអ្នកដទៃ ។

ខ្ញុំបានរៀនថា វិធីដើម្បីមានធនធានបន្ថែមមួយ គឺខ្ញុំត្រូវចំណាយតិចជាងអ្វីដែលខ្ញុំរកបាន ។ ដោយមានធនធានបន្ថែមនោះ ខ្ញុំអាចបង្ហាញពីបទពិសោធន៍ដ៏រីករាយថា ការផ្តល់ឲ្យគឺប្រសើរជាងការទទួល ។ នោះគឺជាមួយចំណែកប៉ុណ្ណោះ ពីព្រោះពេលយើងផ្តល់ជំនួយតាមរបៀបរបស់ព្រះអម្ចាស់ នោះទ្រង់ប្រទានដល់យើង ។

ប្រធាន ម៉ារ៉ុន ជី រ៉មនី បានលើកឡើងពីកិច្ចការសុខុមាលភាពថា « ក្នុងកិច្ចការនេះ អ្នកមិនអាចផ្តល់ឲ្យហួតដល់អ្នកធ្លាក់ខ្លួនក្រនោះឡើយ » ។ រួចហើយលោកបានដកស្រង់ពាក្យរបស់ប្រធានបេសកកម្មលោក គឺ លោក មេលវិន ជី បាឡាដ តាមរបៀបនេះថា ៖ « បើមនុស្សម្នាក់ថ្វាយរបស់តូចមួយដល់ព្រះអម្ចាស់ នោះទ្រង់នឹងប្រទានពរជ័យដ៏ធំដល់អ្នកនោះវិញ » ។[3]

ខ្ញុំបានដឹងថារឿងនេះពិតមែន នៅក្នុងជីវិតខ្ញុំ ។ ពេលខ្ញុំមានចិត្តសប្បុរសចំពោះកូនចៅដែលទ័លក្ររបស់ព្រះវរបិតាសួគ៌ នោះទ្រង់នឹងមានព្រះទ័យសប្បុរសចំពោះខ្ញុំវិញ ។

គោលការណ៍នៃដំណឹងល្អទីពីរដែលបានក្លាយជាការណែនាំមួយសម្រាប់ខ្ញុំក្នុងកិច្ចការសុខុមាលភាព គឺជាអំណាចនិងពរជ័យនៃសាមគ្គីភាព ។ ប្រធាន ជេ រ៉ូបឺន ក្លាក ជុញ្ញ័រ បានមានប្រសាសន៍តាមរបៀបនេះថា ៖

« ប្រហែលជា ...ការផ្តល់ឲ្យនោះបាននាំមកនូវអារម្មណ៍នៃភាពជាបងប្អូនប្រុស ដោយសារបុរសដែលគ្រប់ជំនាញនិងគ្រប់ការងារបានធ្វើការរួមគ្នាក្នុងកម្មវិធីសុខុមាលភាព ឬគម្រោងផ្សេងទៀត » ។[4]

ការកើនឡើងនូវអារម្មណ៍នៃភាពជាបងប្អូនប្រុសនោះ គឺពិតចំពោះទាំងអ្នកទទួលនិងអ្នកផ្តល់ឲ្យ ។ រហូតមកដល់សព្វថ្ងៃនេះ បុរសម្នាក់ដែលខ្ញុំបានកើបភក់ក្បែរគាត់ក្នុងផ្ទះគាត់នៅ រ៉េក្សប៊ឺហ្គ ដែលត្រូវទឹកលិច មាននូវចំណងមួយនឹងខ្ញុំ ។ ហើយគាត់មាននូវភាពថ្លៃថ្នូរផ្ទាល់ខ្លួនដ៏ធំចំពោះអ្វីៗដែលគាត់អាចធ្វើសម្រាប់ខ្លួនឯងនិងគ្រួសារ ។ បើយើងបានធ្វើការតែឯង នោះយើងទាំងពីរនាក់នឹងបាត់បង់នូវពរជ័យខាងវិញ្ញាណមួយ ។

ការណ៍នោះបានដឹកនាំទៅរកគោលការណ៍ទីបីនៃសកម្មភាពក្នុងកិច្ចការសុខុមាលភាពសម្រាប់ខ្ញុំគឺ ៖ ការឲ្យគ្រួសារអ្នកប្រឡូកក្នុងកិច្ចការនោះជាមួយអ្នក ដើម្បីគេអាចរៀនមើលថែគ្នាទៅវិញទៅមក ដូចដែលពួកគេបានមើលថែដល់អ្នកដទៃដែរ ។ កូនប្រុសស្រីអ្នកដែលធ្វើការជាមួយនឹងអ្នកក្នុងការបម្រើដល់អ្នកដទៃដែលទ័លក្រ នឹងចេះជួយគ្នាទៅវិញទៅមកពេលគេមានសេចក្តីត្រូវការ ។

គោលការណ៍ដ៏មានតម្លៃទីបួននៃសុខុមាលសាសនាចក្រដែលខ្ញុំបានរៀនក្នុងនាមជាប៊ីស្សព ។ វាកើតចេញពីការធ្វើតាមបញ្ញាក្នុងព្រះគម្ពីរដើម្បីស្វែងរកអ្នកក្រីក្រ ។ វាគឺជាកាតព្វកិច្ចរបស់ប៊ីស្សពដើម្បីស្វែងរក ហើយផ្តល់ជំនួយដល់អ្នកដែលនៅត្រូវការជំនួយ បន្ទាប់ពីគេនិងគ្រួសារគេធ្វើអ្វីៗគ្រប់យ៉ាងរួចមក ។ ខ្ញុំបានរកឃើញថា ព្រះអម្ចាស់បានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធដើម្បីអាច« រកនោះតែនឹងឃើញ »[5] ក្នុងការមើលថាអ្នកក្រីក្រដូចគ្នានឹងការស្វែងរកសេចក្តីពិតដែរ ។

អ្នករាល់គ្នាមួយចំនួនត្រូវការការបំផុសគំនិតនោះប៉ុន្មានខែមុន ។ ដើម្បីរំឭកដល់ខួបលើកទី 75 នៃកម្មវិធីសុខុមាលភាពសាសនាចក្រ សមាជិកទូទាំងពិភពលោកនឹងត្រូវបានអញ្ជើញឲ្យចូលរួមក្នុង « ទិវានៃការបម្រើ » មួយ ។ ពួកអ្នកដឹកនាំនិងសមាជិកនឹងស្វែងរកវិវរណៈ ពេលគេរៀបចំគម្រោងនោះ ។

ខ្ញុំនឹងផ្តល់នូវពាក្យណែនាំចំនួនបី ពេលអ្នករៀបចំគម្រោងនៃការបម្រើរបស់អ្នក ។

ទីមួយ សូមរៀបចំខ្លួនអ្នកខាងវិញ្ញាណ ។ មានតែដួងចិត្តដែលត្រូវបានបន្ទន់ដោយដង្វាយធួនរបស់ព្រះអង្គសង្គ្រោះប៉ុណ្ណោះ ដែលអ្នកអាចយ៉ាងច្បាស់ពីគោលដៅនៃគម្រោងដើម្បីប្រទានពរដល់ជីវិតនៃកូនចៅព្រះវរបិតាសួគ៌ទាំងខាងវិញ្ញាណនិងខាងសាច់ឈាម ទាំងជាបុគ្គលម្នាក់ៗ ឬជាផ្នែកនៃសហគមន៍មួយ ។

ពាក្យណែនាំទីពីររបស់ខ្ញុំគឺការរើសអ្នកទទួលការបម្រើរបស់អ្នក ជាមនុស្សដែលតម្រូវការរបស់គេធ្វើឲ្យពួកអ្នកជួយមានការអាណិតអាសូរ ។ មនុស្សដែលអ្នកបម្រើនឹងយល់ពីក្តីស្រឡាញ់អ្នក ។ ការណ៍នោះអាចធ្វើច្រើនដើម្បីធ្វើឲ្យពួកគេមានអារម្មណ៍រីករាយ ដូចជាចម្រៀងដែលបានសន្យា ជាងការបំពេញតម្រូវការខាងសាច់ឈាមរបស់គេ ។

ពាក្យណែនាំចុងក្រោយរបស់ខ្ញុំគឺការរៀបចំប្រើអំណាចនៃចំណងគ្រួសារ នៃកូរ៉ុម នៃអង្គការជំនួយ និងមនុស្សដែលអ្នកស្គាល់ក្នុងសហគមន៍របស់អ្នក ។ អារម្មណ៍នៃសាមគ្គីភាពនឹងបែងចែកផលល្អនៃការបម្រើដែលអ្នកផ្តល់ ។ ហើយអារម្មណ៍នៃសាមគ្គីភាពទាំងនោះក្នុងគ្រួសារ ក្នុងសាសនា-ចក្រ និងក្នុងសហគមន៍រីកចម្រើន ហើយនឹងក្លាយជាកេរមរតកដ៏យូរអង្វែងបន្ទាប់ពីគម្រោងនេះបានបញ្ចប់ ។

នេះគឺជាឱកាសរបស់ខ្ញុំដើម្បីប្រាប់អ្នកពីអំណរគុណដ៏ធំធេងដែលខ្ញុំមានចំពោះអ្នក ។ ដោយការបម្រើនៃក្តីស្រឡាញ់ដែលអ្នកបានថ្វាយដល់ព្រះអម្ចាស់ មនុស្សដែលបានអ្នកបានជួយ បានថ្លែងអំណរគុណដល់ខ្ញុំពេលគេជួបខ្ញុំ ។

អ្នកបានរកឃើញវិធីមួយដើម្បីធ្វើឲ្យគេរីករាយ ពេលអ្នកជួយតាមវិធីរបស់ព្រះអម្ចាស់ ។ អ្នកនិងពួកសិស្សដ៏រាបសានៃព្រះអង្គសង្គ្រោះដូចជាអ្នក បានផ្តល់ការបម្រើដោយអស់ពីចិត្តដល់អ្នកដទៃ ហើយមនុស្សដែលអ្នកបានជួយបានសម្តែងការដឹងគុណដ៏ធំធេងចំពោះអ្នកតាមរយៈខ្ញុំ ។

ខ្ញុំបានទទួលនូវអារម្មណ៍នៃការដឹងគុណដូចគ្នាពីមនុស្សដែលបានធ្វើការជាមួយនឹងអ្នក ។ ខ្ញុំចាំថា មានគ្រាមួយពេលឈរជិតនឹងប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ។ យើងបាននិយាយពីការបម្រើក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ ។ លោកបានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលពីកម្លាំងដ៏រឹងមាំរបស់លោក ពេលលោកបានលើកដៃឡើង ហើយមានប្រសាសន៍ថា « ខ្ញុំចូលចិត្តកិច្ចការនេះ ហើយវាដំណើរការមែន ! »[6]

ជំនួសឲ្យលោកចៅហ្វាយ ខ្ញុំសូមសម្ដែងអំណរគុណចំពោះកិច្ចការអ្នកក្នុងការបម្រើដល់កូនចៅនៃព្រះវរបិតាសួគ៌យើង ។ ទ្រង់ស្គាល់អ្នក ហើយទ្រង់ទតឃើញពីការខិតខំ ការឧស្សាហ៍ និងការលះបង់របស់អ្នក ។ ខ្ញុំសូមអធិស្ឋានថា ទ្រង់នឹងប្រទានឲ្យអ្នកនូវពរជ័យនៃការមើលឃើញផលផ្លែនៃកិច្ចការរបស់អ្នកក្នុងសុភមង្គលនៃមនុស្សដែលអ្នកបានជួយជំនួសព្រះអម្ចាស់ ។

ខ្ញុំដឹងថា ព្រះជាព្រះវរបិតាមានព្រះជន្មរស់ ហើយឮការអធិស្ឋានអ្នក ។ ខ្ញុំដឹងថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។ អ្នកនិងមនុស្សដែលអ្នកបម្រើអាចធ្វើឲ្យបរិសុទ្ធ និងទទួលការពង្រឹងដោយការបម្រើទ្រង់ និងការគោរពតាមព្រះបញ្ញត្តិទ្រង់ ។ អ្នកអាចដឹងដូចជាខ្ញុំដឹង ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ថាគឺជាព្យាការីរបស់ព្រះ ដើម្បីស្ដារសាសនាចក្រពិតហើយសកម្ម ដែលជាសាសនាចក្រនេះ ។ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. « Have I Done Any Good? » *Hymns* ទំព័រ 223 ។
2. សូមមើល « កិច្ចការដំផ្ដើម » *ទំនុកតម្កើង* ទំព័រ 13 ។
3. Marion G. Romney « Welfare Services: The Savior's Program » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1980 ទំព័រ 93 ។
4. J. Reuben Clark Jr. ក្នុង Conference Report ខែ តុលា ឆ្នាំ 1943 ទំព័រ 13 ។
5. សូមមើល ម៉ាថាយ 7:7–8 លូកា 11:9–10 នីហ្វៃទី 3 14:7–8 ។
6. គោលលទ្ធិ និង សេចក្ដីសញ្ញា 81:5 ។